គណៈកម្មការគ្រប់គ្រង
និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

# កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹង គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ ទេសចរណ៍សៀមរាប-អង្គរ

ឆ្នាំ២០២២

# មាតិកា

១. អនុក្រឹត្យ ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

២. សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

៣. សេចក្តីសម្រេច ស្តីពី ការរៀបចំ និងប្រព្រឹត្តិទៅរបស់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

៤. សេចក្តីសម្រេច ស្តីពី ការតែងតាំងសមាសភាពគណៈប្រតិបត្តិនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

៥. សេចក្តីសម្រេច ស្តីពី ការតែងតាំងសមាសភាពអនុគណៈកម្មការនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

៦. សេចក្តីសម្រេច ស្តីពី ការតែងតាំងសមាសភាពលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- យោងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដែលសរសេរជាអក្សរកាត់ថា **គ.អ.ទ.ស.** ដើម្បីដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យការអភិវឌ្ឍគោលដៅទេសចរណ៍ខេត្តសៀមរាប ដោយអនុវត្តតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥ ឱ្យមានប្រសិទ្ធភាពសំដៅបង្កើនភាពប្រកួតប្រជែង និងធានាបាននូវនិរន្តរភាព។

**មាត្រា ២._**

ការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍នៅតាមតំបន់ទេសចរណ៍អាទិភាពត្រូវមានអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ គ.អ.ទ.ស.។

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវបានបង្កើតឡើងតាមតំបន់ចំនួន៦ ដូចខាងក្រោម÷

**១.** តំបន់ឧទ្យានជាតិភ្នំគូលែន

**២.** តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី

**៣.** តំបន់បេតិកភណ្ឌអង្គរ

**៤.** តំបន់ក្រុងសៀមរាប

**៥.** តំបន់បឹងទន្លេសាប

**៦.** តំបន់ទេសចរណ៍សៀមរាបថ្មី។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន គ.អ.ទ.ស.។

សមាសភាពជាក់ស្តែងនៃអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវសម្រេចដោយសេចក្ដីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍។

ចំពោះ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បេតិកភណ្ឌអង្គរ គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរជាតិអប្សរា។

## ជំពូកទី ២

## សមាសភាព

**មាត្រា ៣._**

**គ.អ.ទ.ស.** មានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |

- រដ្ឋមន្ត្រីក្រសួងបរិស្ថាន អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម សមាជិក
- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក
- រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក
- រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក
- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អគ្គស្នងការនគរបាលជាតិ សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- អភិបាលនៃគណៈអភិបាលខេត្តសៀមរាប សមាជិកប្រចាំការ
- អគ្គនាយកអាជ្ញាធរជាតិអប្សរា សមាជិក
- អគ្គនាយកគ្រឹះស្ថានអង្គរ សមាជិក
- អគ្គនាយកអគ្គិសនីកម្ពុជា សមាជិក
- តំណាងក្រសួងទេសចរណ៍ ០៣រូប សមាជិក
- តំណាងអាជ្ញាធរទន្លេសាប សមាជិក
- តំណាងក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា សមាជិក
- ប្រធានលេខាធិការដ្ឋាន គ.អ.ទ.ស. សមាជិក

សមាសភាពជាក់ស្តែងនៃ គ.អ.ទ.ស. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា ៤._**

គ.អ.ទ.ស. មានតួនាទី និងភារកិច្ច ដូចតទៅ÷

- សម្របសម្រួល ចាត់ចែង អនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥
- ពង្រឹងការអភិវឌ្ឍផលិតផលទេសចរណ៍ បម្រើសេចក្តីត្រូវការរបស់ភ្ញៀវទេសចរឱ្យបានសម្បូរបែប និងអាចផ្តល់បទពិសោធន៍ល្អៗ ដើម្បីជាការចងចាំដល់ភ្ញៀវទេសចរក្នុងដំណើរកម្សាន្ត
- ពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ អមជាមួយការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធ
- ផ្សព្វផ្សាយតំបន់/គោលដៅទេសចរណ៍របស់ខ្លួនទៅកាន់ទីផ្សារទេសចរណ៍ជាតិ និងអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើគម្រោងវិនិយោគសាធារណៈ និងឯកជនបម្រើឱ្យការអភិវឌ្ឍវិស័យទេសចរណ៍សៀមរាប-អង្គរ ជូនស្ថាប័នមានសមត្ថកិច្ច
- ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- គាំទ្រជាមូលនិធិ ដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍នៅក្នុងតំបន់សៀមរាប-អង្គរ
- ទទួលខុសត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងសម្របសម្រួលការអភិវឌ្ឍទេសចរណ៍ឱ្យស្របតាមផែនការអភិវឌ្ឍន៍ទេសចរណ៍ ថ្នាក់តំបន់ និងថ្នាក់ជាតិ
- ពិនិត្យ សិក្សា និងលើកសំណើធ្វើបច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥ ឱ្យស្របតាមសភាពការណ៍ និងការវិវត្តន៍នៃវិស័យទេសចរណ៍កម្ពុជា
- រៀបចំសូចនាករគន្លឹះសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ផែនការមេ
- ធ្វើរបាយការណ៍ការងារប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

## ជំពូកទី៤
## កិច្ចដំណើរការការងារ

**មាត្រា ៥._**

**គ.អ.ទ.ស.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានអចិន្ត្រៃយ៍តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**គ.អ.ទ.ស.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

**គ.អ.ទ.ស.** មានត្រាដោយឡែករបស់ខ្លួនក្នុងកិច្ចដំណើរការប្រចាំថ្ងៃ ដែលជាឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

**មាត្រា ៦._**

**គ.អ.ទ.ស.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនឱ្យចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខណ្ឌការងាររបស់ខ្លួន។

**មាត្រា ៧._**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.អ.ទ.ស. ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន គ.អ.ទ.ស.។

**មាត្រា ៨._**

**គ.អ.ទ.ស.** មានអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋាន អាចមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ដែលជាតំណាងមកពីរដ្ឋបាលខេត្តសៀមរាប និងតំណាងអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក។

តួនាទី ភារកិច្ច និងសមាសភាពជាក់ស្ដែងរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន គ.អ.ទ.ស. ។

អង្គការលេខរបស់ គ.អ.ទ.ស. ជាឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា ៩._**

ថវិកាចំណាយសម្រាប់ដំណើរការរបស់លេខាធិការដ្ឋាននៃ **គ.អ.ទ.ស.** ត្រូវគាំទ្រដោយថវិកាជាតិទៅតាមលទ្ធភាពនៃថវិកាប្រចាំឆ្នាំ ក្នុងគម្រោងថវិកាកម្មវិធីរបស់ក្រសួងទេសចរណ៍។

**គ.អ.ទ.ស.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវធនធាន និងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់ជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១០._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ..២៧៦.......អនក្រ.បកចុះថ្ងៃទី..៣០...ខែ.ធ្នូ.....ឆ្នាំ២០២១**

**ស្តីពី**

**ការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

## រចនាសម្ព័ន្ធនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

### គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

### គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

ក្រុមពិគ្រោះយោបល់ គណៈកម្មាធិការអន្តរជាតិសម្រប សម្រួលកិច្ចគាំពារនិងការអភិវឌ្ឍ តំបន់ប្រវត្តិសាស្ត្រអង្គរ

- Sub-DMO តំបន់ឧទ្យានជាតិភ្នំគូលែន
- Sub-DMO តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី
- Sub-DMO តំបន់អង្គរ (អាជ្ញាធរជាតិអប្សរា)
- Sub-DMO តំបន់ក្រុងសៀមរាប
- Sub-DMO តំបន់បឹងទន្លេសាប
- Sub-DMO តំបន់ទេសចរណ៍សៀមរាបថ្មី។

យន្តការស្ថាប័នគាំទ្រ

- អាជ្ញាធរជាតិអប្សរា
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- គ្រឹះស្ថានអង្គរ
- ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (សាខាខេត្តសៀមរាប)
- សាលាជាតិវិជ្ជាជីវៈទេសចរណ៍ (សាខាខេត្តសៀមរាប)
- រដ្ឋាករស្វយ័តសំរាមខេត្តសៀមរាប
- រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប
- ទូរគមនាគមន៍កម្ពុជា
- អគ្គិសនីកម្ពុជាប្រចាំខេត្តសៀមរាប។

**សម្គាល់÷** ICC-Angkor ជាយន្តការពិគ្រោះយោបល់ ទៅលើគម្រោងដែលពាក់ព័ន្ធនឹងតំបន់បេតិកភណ្ឌពិភពលោក (តំបន់ប្រាសាទបុរាណដ្ឋាននៅភ្នំគូលែន និងស្ទឹងសៀមរាប) និងតំបន់បេតិកភណ្ឌនានា ដើម្បីធានាគុណតម្លៃនៃរមណីយដ្ឋានអង្គរ។

ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ...២៧៦......អនក្រ.បកចុះថ្ងៃទី...៣០...ខែ..៥.....ឆ្នាំ២០២១

ស្ដីពី

ការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

គំរូត្រានៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ២៧ សសរ**

## សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍

- បានឃើញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមសំណើរបស់ប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## សម្រេច

**ប្រការ១.**_

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា | អនុប្រធាន |
| ៤. ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៥. ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦. ឯកឧត្តម **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប | សមាជិក |
| ៧. ឯកឧត្តម **ជា វ៉ាន់ដេត** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៨. ឯកឧត្តម **ម៉ម ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ៩. ឯកឧត្តម **ឈិត សុខុន** | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | សមាជិក |
| ១០. ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១. ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១២. ឯកឧត្តម **និត ចន្ថា** | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ | សមាជិក |
| ១៣. ឯកឧត្តម **កុល ធីរក្ស** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. ឯកឧត្តម **កែន សត្ថា** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥. ឯកឧត្តមបណ្ឌិត **ឈុន សុគាត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៦. ឯកឧត្តម **ជា បូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៧. ឯកឧត្តម **សុខ គុងហាប់** | តំណាងក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា | សមាជិក |

| | | |
|---|---|---|
| ១៨. ឯកឧត្តម **តុប សុគ័ត** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៩. ឯកឧត្តម **ញ៉ើម ខេមរា** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២០. ឯកឧត្តម **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២១. ឯកឧត្តម **ជួន ចន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ២២. ឯកឧត្តម **សុខ ខាត់ចាន់** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២៣. ឯកឧត្តម **ហាប់ អុម៉ាលី** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២៤. ឯកឧត្តម **ឡៅ ហ៊ុម** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៥. ឯកឧត្តម **ហាស់ សារ៉េត** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៦. ឯកឧត្តម **សុខ ចិន្តាសោភា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២៧. ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២៨. ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៩. ឯកឧត្តម **ឌៀ សីហា** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិកប្រចាំការ |
| ៣០. ឯកឧត្តម **សុខ សប្បាយណនា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣១. ឯកឧត្តម **ហង់ ពៅ** | អគ្គនាយកអាជ្ញាធរជាតិអប្សរា | សមាជិក |
| ៣២. ឯកឧត្តម **លី សែ** | អគ្គនាយកគ្រឹះស្ថានអង្គរ | សមាជិក |
| ៣៣. ឯកឧត្តម **កែច រតនៈ** | អគ្គនាយកអគ្គិសនីកម្ពុជា | សមាជិក |
| ៣៤. ឯកឧត្តម **ខុច មាស** | អគ្គលេខាធិការរងអាជ្ញាធរទន្លេសាប | សមាជិក |
| ៣៥. ឯកឧត្តម **ណោប សាមុត** | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាប្រធានលេខាធិការដ្ឋាន គ.អ.ទ.ស. | សមាជិក។ |

**ប្រការ២._**

សមាជិកនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ មានភារកិច្ចអនុវត្តការងារ ទៅតាមការតម្រង់ទិសរបស់អនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ**នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍
ទេសចរណ៍សៀមរាប-អង្គរ
លេខ:០០១ សសរ.គ.ស.ទ.ស.

# សេចក្ដីសម្រេច
# ស្ដីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## ប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

សេចក្តីសម្រេចនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដែលសរសេរជាអក្សរកាត់ថា "**គ.អ.ទ.ស.**"។

**ប្រការ២._**

ការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍នៅតាមតំបន់ទេសចរណ៍អាទិភាពត្រូវមានអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ គ.អ.ទ.ស.។

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវបានបង្កើតឡើងតាមតំបន់ចំនួន៦ រួមមានដូចខាងក្រោម÷

១. តំបន់ឧទ្យានជាតិភ្នំគូលែន

២. តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី

៣. តំបន់បេតិកភណ្ឌអង្គរ

៤. តំបន់ក្រុងសៀមរាប

៥. តំបន់បឹងទន្លេសាប

៦. តំបន់ទេសចរណ៍សៀមរាបថ្មី។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវបកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.អ.ទ.ស.។

សមាសភាពជាក់ស្តែងនៃអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវសម្រេចដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍។

ចំពោះ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បេតិកភណ្ឌអង្គរ គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរជាតិអប្សរា។

## ជំពូកទី២

## តួនាទី និងភារកិច្ច

**ប្រការ៣._**

គ.អ.ទ.ស. មានតួនាទី និងភារកិច្ច ដូចតទៅ÷

- សម្របសម្រួល ចាត់ចែង អនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ ២០២១-២០៣៥
- ពង្រឹងការអភិវឌ្ឍផលិតផលទេសចរណ៍ បម្រើសេចក្តីត្រូវការរបស់ភ្ញៀវទេសចរឱ្យបានសម្បូរបែប និងអាចផ្តល់បទពិសោធន៍ល្អៗ ដើម្បីជាការចងចាំដល់ភ្ញៀវទេសចរក្នុងដំណើរកម្សាន្ត



៧

- ពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ អមជាមួយការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធ
- ផ្សព្វផ្សាយតំបន់/ គោលដៅទេសចរណ៍របស់ខ្លួនទៅកាន់ទីផ្សារទេសចរណ៍ជាតិ និងអន្តរជាតិ
- ពិនិត្យ និងផ្តល់យោបល់លើគម្រោងវិនិយោគសាធារណៈ និងឯកជនបម្រើឱ្យការអភិវឌ្ឍវិស័យទេសចរណ៍សៀមរាប-អង្គរ ជូនស្ថាប័នមានសមត្ថកិច្ច
- ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- គាំទ្រជាមូលនិធិ ដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍នៅក្នុងតំបន់សៀមរាប-អង្គរ
- ទទួលខុសត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងសម្របសម្រួលការអភិវឌ្ឍទេសចរណ៍ឱ្យស្របតាមផែនការអភិវឌ្ឍន៍ទេសចរណ៍ ថ្នាក់តំបន់ និងថ្នាក់ជាតិ
- ពិនិត្យ សិក្សា និងលើកសំណើធ្វើបច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥ ឱ្យស្របតាមសភាពការណ៍ និងការវិវត្តន៍នៃវិស័យទេសចរណ៍កម្ពុជា
- រៀបចំសូចនាករគន្លឹះសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ផែនការមេ
- ធ្វើរបាយការណ៍ការងារប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

**ប្រការ៤._**

គ.អ.ទ.ស. មានគណៈប្រតិបត្តិមួយ ជាសេនាធិការប្រចាំការ ដែលមានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | អនុប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| - រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |



7

- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក
- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អគ្គស្នងការនគរបាលជាតិ សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- អគ្គនាយកអាជ្ញាធរជាតិអប្សរា សមាជិក
- អគ្គនាយកគ្រឹះស្ថានអង្គរ សមាជិក
- អគ្គនាយកអគ្គិសនីកម្ពុជា សមាជិក
- តំណាងក្រសួងទេសចរណ៍ ០៥ (ប្រាំ) រូប សមាជិក
- តំណាងអាជ្ញាធរទន្លេសាប សមាជិក
- តំណាងក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា សមាជិក
- ប្រធានលេខាធិការដ្ឋាន គ.អ.ទ.ស. សមាជិក
- អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- អគ្គនាយករងអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ ១ (មួយ) រូប សមាជិក។

**ប្រការ៥._**

គណៈប្រតិបត្តិនៃ គ.អ.ទ.ស. អាចមានសមាសភាពចូលរួមផ្សេងទៀត តាមការចាំបាច់។ សមាសភាពជាក់ស្តែងនៃគណៈប្រតិបត្តិ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.អ.ទ.ស.។

ប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស. អាចអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ៦._**

គណៈប្រតិបត្តិនៃ គ.អ.ទ.ស. មានភារកិច្ចដូចតទៅ÷

- ដឹកនាំការអនុវត្តបទបញ្ជា និងការណែនាំនានារបស់ប្រធាន គ.អ.ទ.ស.
- ដឹកនាំ និងសម្របសម្រួលសម្របអនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥

- ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលការងារប្រចាំថ្ងៃរបស់ គ.អ.ទ.ស. អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក និងយន្តការនានាដែលចំណុះឱ្យ គ.អ.ទ.ស. ព្រមទាំងយន្តការពាក់ព័ន្ធផ្សេងទៀតលើការអនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥
- ណែនាំ និងសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីធានាដល់និរន្តរភាពនៃកិច្ចដំណើរការ
- រាយការណ៍ផ្ទាល់ និងជាប្រចាំជូនប្រធាន គ.អ.ទ.ស.
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធាន គ.អ.ទ.ស.។

## ជំពូកទី៣

## យន្តការអនុវត្តចំណុះឱ្យ គ.អ.ទ.ស.

**ប្រការ៧._**

គ.អ.ទ.ស. មានអនុគណៈកម្មការ ចំនួន ០៥ (ប្រាំ) ដូចខាងក្រោម÷

- អនុគណៈកម្មការអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- អនុគណៈកម្មការផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍
- អនុគណៈកម្មការពង្រឹងគុណភាព និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍
- អនុគណៈកម្មការគ្រប់គ្រងបរិស្ថាន
- អនុគណៈកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់។

**ប្រការ៨._**

អនុគណៈកម្មការអភិវឌ្ឍន៍ផលិតផលទេសចរណ៍ មានភារកិច្ចដូចខាងក្រោម÷

- ពង្រឹងការអភិវឌ្ឍន៍ផលិតផលទេសចរណ៍ បម្រើឱ្យសេចក្តីត្រូវការរបស់ភ្ញៀវទេសចរណ៍ឱ្យបានសម្បូរបែប និងអាចផ្តល់បទពិសោធន៍ល្អៗ ដើម្បីជាការចងចាំដល់ភ្ញៀវទេសចរណ៍ក្នុងដំណើរកម្សាន្ត
- សិក្សា និងរៀបចំបង្កើតសៀគ្វី និងខ្សែធ្វើដំណើរទេសចរណ៍បេតិកភណ្ឌពិភពលោក
- សិក្សា និងបង្កើតសារមន្ទីរអរិយធម៌
- សិក្សា និងអភិវឌ្ឍន៍ទេសចរណ៍ច្នៃប្រឌិតផ្សារភ្ជាប់នឹងឧស្សាហកម្មច្នៃប្រឌិត
- សិក្សាបង្កើត និងពង្រឹងឧបករណ៍ និងមធ្យោបាយបកស្រាយពន្យល់បេតិកភណ្ឌ និងវប្បធម៌ដល់ភ្ញៀវទេសចរណ៍
- សិក្សាស្រាវជ្រាវ និងរៀបចំអភិវឌ្ឍន៍ទេសចរណ៍បៃតងក្នុងតំបន់សៀមរាប-អង្គរ ស្របតាមស្តង់ដាបៃតងអាស៊ាន និងកម្ពុជា
- រៀបចំ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ម៉ាយ (MICE) នៅក្នុងតំបន់សៀមរាប-អង្គរ
- រៀបចំ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍ ដោយផ្អែកលើការធ្វើសមាហរណកម្មក្នុងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍជនបទ
- រៀបចំ និងអភិវឌ្ឍន៍ផលិតផលកីឡាទេសចរណ៍ក្នុងតំបន់សៀមរាប-អង្គរ
- រាយការណ៍ផ្ទាល់ និងជាប្រចាំជូនប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.

- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.។

**ប្រការ៩._**

អនុគណៈកម្មការផ្សព្វផ្សាយទាក់ទាញទេសចរណ៍ មានភារកិច្ចដូចខាងក្រោម÷

- សិក្សា និងជំរុញការផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍សៀមរាប-អង្គរទៅកាន់ទីផ្សារតំបន់ និងពិភពលោក តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ
- ជំរុញ និងបង្កើនការរៀបចំចងក្រងបោះពុម្ពឯកសារ និងផ្សព្វផ្សាយទេសចរណ៍ជាភាសាបរទេសជាអាទិភាព
- សិក្សា និងជំរុញការទាក់ទាញទេសចរពីប្រភពទីផ្សារទេសចរណ៍សំខាន់
- សិក្សា និងរៀបចំផែនការបង្កើនឧត្តមភាពប្រកួតប្រជែងនៃគោលដៅទេសចរណ៍សៀមរាប-អង្គរ
- រៀបចំ និងបង្កើនកិច្ចសហការជាមួយដៃគូសារព័ត៌មានជាតិ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយគោលដៅទេសចរណ៍សៀមរាប-អង្គរ
- ជំរុញការផ្សព្វផ្សាយទេសចរណ៍សៀមរាប-អង្គរ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល (Digital Marketing)
- សិក្សា និងបង្កើតម៉ាកទេសចរណ៍សម្រាប់តំបន់ទេសចរណ៍សៀមរាប-អង្គរ អមជាមួយការប្រើប្រាស់ និងផ្សព្វផ្សាយ "កម្ពុជា: ព្រះរាជាណាចក្រអច្ឆរិយៈ - ផ្ដល់ភាពកក់ក្ដៅ"
- រាយការណ៍ផ្ទាល់ និងជាប្រចាំជូនប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.។

**ប្រការ១០._**

អនុគណៈកម្មការពង្រឹងគុណភាព និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍ មានភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងពង្រឹងគុណភាពគុណភាពឧស្សាហកម្មទេសចរណ៍ក្នុងតំបន់សៀមរាប-អង្គរឱ្យស្របតាមស្តង់ដាកម្ពុជា និងអាស៊ាន
- រៀបចំ និងពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ក្នុងតំបន់សៀមរាប-អង្គរ តាមរយៈស្តង់ដាចំណាត់ថ្នាក់
- រៀបចំ និងពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ក្នុងតំបន់សៀមរាប-អង្គរ តាមរយៈការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្ត
- សិក្សា និងពង្រឹងភាពធន់នៃវិស័យទេសចរណ៍ក្នុងតំបន់សៀមរាប-អង្គរ ឆ្លើយតបនឹងគ្រោះមហន្តរាយ វិបត្តិជំងឺឆ្លង និងវិបត្តិនានា
- សិក្សា និងរៀបចំផែនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ ដើម្បីបង្កើនសមត្ថភាពផ្គត់ផ្គង់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
- សិក្សា និងរៀបចំពង្រឹងការបណ្តុះបណ្តាលសហគ្រិនភាព គំនិតច្នៃប្រឌិត និងធុរកិច្ចក្នុងវិស័យទេសចរណ៍
- សិក្សា និងពង្រឹងការធានាសុខុមាលភាពបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍
- សិក្សា វាយតម្លៃ និងពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានតាមរយៈការអភិវឌ្ឍវិស័យទេសចរណ៍
- រាយការណ៍ផ្ទាល់ និងជាប្រចាំជូនប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.



7

- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.។

**ប្រការ១១._**

អនុគណៈកម្មការគ្រប់គ្រងបរិស្ថាន មានភារកិច្ចដូចខាងក្រោម÷

- សិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងតំបន់សៀមរាប-អង្គរ
- សិក្សា និងរៀបចំការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងតំបន់សៀមរាប-អង្គរ
- សិក្សា និងរៀបចំបង្កើតប្រព័ន្ធហិរញ្ញវត្ថុសម្រាប់កិច្ចគាំពារបរិស្ថានក្នុងតំបន់សៀមរាប-អង្គរ
- ពង្រឹងចលនាប្រឡងប្រណាំង “ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ”
- រៀបចំ និងពង្រឹងការលើកកម្ពស់តំបន់បៃតងក្នុងតំបន់សៀមរាប-អង្គរ
- សិក្សា និងសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីសម្របសម្រួល និងការពារប្រព័ន្ធអេកូឡូស៊ីធម្មជាតិក្នុងតំបន់សៀមរាប-អង្គរ
- រាយការណ៍ផ្ទាល់ និងជាប្រចាំជូនប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.។

**ប្រការ១២._**

អនុគណៈកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់ មានភារកិច្ចដូចខាងក្រោម÷

- សហការ និងជំរុញការតភ្ជាប់ផ្ទៃក្នុង សម្រាប់តំបន់សៀមរាប-អង្គរ
- សហការ និងជំរុញការតភ្ជាប់ផ្ទៃក្នុងមកកាន់តំបន់សៀមរាប-អង្គរ
- សហការ និងជំរុញការតភ្ជាប់ពីអន្តរជាតិមកតំបន់សៀមរាប-អង្គរ
- សហការ និងសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ឱ្យមានភាពបត់បែន និងងាយស្រួល
- សិក្សា និងសហការរៀបចំការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតបម្រើឱ្យវិស័យទេសចរណ៍ក្នុងតំបន់សៀមរាប-អង្គរ
- សហការពង្រឹង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីបម្រើឱ្យវិស័យទេសចរណ៍ក្នុងតំបន់សៀមរាប-អង្គរ
- រាយការណ៍ផ្ទាល់ និងជាប្រចាំជូនប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.។

**ប្រការ១៣._**

សមាសភាពជាក់ស្តែងនៃអនុគណៈកម្មការនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.។

**ប្រការ១៤._**

គ.អ.ទ.ស. មានក្រុមពិគ្រោះយោបល់មួយ ដោយមានការចូលរួមពីឥស្សរជន អ្នកជំនាញការជាតិ និងអន្តរជាតិ ដើម្បីពិគ្រោះយោបល់លើការអភិវឌ្ឍទេសចរណ៍តំបន់សៀមរាប-អង្គរ។

សមាសភាពជាក់ស្តែងនៃក្រុមពិគ្រោះយោបល់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.អ.ទ.ស.។



ý

# ជំពូកទី៤
# លេខាធិការដ្ឋាននៃ គ.អ.ទ.ស.
## ផ្នែកទី១
## តួនាទី និងភារកិច្ច

**ប្រការ១៥._**

លេខាធិការដ្ឋាននៃ គ.អ.ទ.ស. មានតួនាទី និងភារកិច្ច ដូចតទៅ÷

- សម្របសម្រួលចាត់ចែងអនុវត្តរាល់សកម្មភាពការងារប្រចាំថ្ងៃរបស់ គ.អ.ទ.ស.
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានទេសចរណ៍ ដែលមានក្នុងតំបន់សៀមរាប-អង្គរ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្មក្នុងតំបន់សៀមរាប-អង្គរ
- ប្រមូលទិន្នន័យ និងធ្វើវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រចំពោះមុខ និងយូរអង្វែងជូន គ.អ.ទ.ស. ក្នុងការកំណត់ទីតាំងគោលដៅបម្រើដល់កិច្ចអភិវឌ្ឍន៍ និងអភិរក្ស
- សហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់សៀមរាប-អង្គរ
- រៀបចំគោលនយោបាយ ទស្សនវិស័យ និងបេសកកម្មរបស់ គ.អ.ទ.ស.
- សម្របសម្រួល និងសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ប្រកបដោយនិរន្តរភាព
- សម្របសម្រួលការងារនានារបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក
- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- ជាសេនាធិការឱ្យគណៈប្រតិបត្តិនៃ គ.អ.ទ.ស. ក្នុងការសម្របសម្រួលការងារជាមួយអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក
- រៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានារបស់ គ.អ.ទ.ស.
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនប្រធានគណៈប្រតិបត្តិ និងប្រធាន គ.អ.ទ.ស.
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈប្រតិបត្តិ និងប្រធាន គ.អ.ទ.ស. ប្រគល់ជូន។

## ផ្នែកទី២
## រចនាសម្ព័ន្ធ និងការគ្រប់គ្រង

**ប្រការ១៦._**

គ.អ.ទ.ស. មានអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍នៃក្រសួងទេសចរណ៍ ជាលេខាធិការដ្ឋានសម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងកិច្ចសហការរវាង



9

ក្រសួង ស្ថាប័ន អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ប្រកបដោយនិរន្តរភាព។

លេខាធិការដ្ឋាននៃ គ.អ.ទ.ស. ដឹកនាំដោយលេខាធិការ ១ (មួយ) រូប ដែលជាអគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍នៃក្រសួងទេសចរណ៍ និងមានលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់។

សមាសភាពជាក់ស្តែងរបស់លេខាធិការដ្ឋាននៃ គ.អ.ទ.ស. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈប្រតិបត្តិ នៃ គ.អ.ទ.ស.។

**ប្រការ១៧._**

លេខាធិការដ្ឋាននៃ គ.អ.ទ.ស. មានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

១. ផ្នែកផែនការ បណ្តុះបណ្តាល និងនីតិកម្ម

២. ផ្នែកសហប្រតិបត្តិការ និងផ្សព្វផ្សាយ

៣. ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ។

ផ្នែកនីមួយៗ ដឹកនាំដោយប្រធាន ១ (មួយ) រូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

ផ្នែកនីមួយៗរបស់លេខាធិការដ្ឋាននៃ គ.អ.ទ.ស. អាចមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈប្រតិបត្តិនៃ គ.អ.ទ.ស.។

**ប្រការ១៨._**

ផ្នែកផែនការ បណ្តុះបណ្តាល និងនីតិកម្ម មានតួនាទី និងភារកិច្ច ដូចតទៅ÷

- ប្រមូល រៀបចំ គ្រប់គ្រង និងវិភាគទិន្នន័យលទ្ធផលការងារដែលទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធ ដើម្បីកំណត់ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ កម្មវិធីនិងផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែងបម្រើដល់ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ស្របតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥
- តាមដាន វាយតម្លៃ ប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាព
- ធ្វើកិច្ចសហការរៀបចំ និងវាយតម្លៃតម្រូវការសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សក្នុងលេខាធិការដ្ឋាននៃ គ.អ.ទ.ស. និងគ្រប់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- ធ្វើកិច្ចសហការរៀបចំកម្មវិធីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីលេខាធិការដ្ឋាននៃ គ.អ.ទ.ស. និងគ្រប់ភាគីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- រៀបចំ អង្កេត និងវាយតម្លៃការអនុវត្តផែនការ និងគម្រោងអភិវឌ្ឍន៍ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដើម្បីជូនយោបល់ប្រធាន គ.អ.ទ.ស. តាមរយៈលេខាធិការនៃ គ.អ.ទ.ស.
- សិក្សាស្រាវជ្រាវឯកសារច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

- រៀបចំកសាងឯកសារច្បាប់ និងលិខិតបទដ្ឋាននានា ដើម្បីគ្រប់គ្រងការងារពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដោយធ្វើកិច្ចសហការជាមួយអង្គភាព និងក្រសួងស្ថាប័នពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹង និងសម្របសម្រួលនូវរាល់វិវាទនានា ដែលកើតមានឡើងក្នុងតំបន់សៀមរាប-អង្គរ
- ចូលរួមផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗដែលមានការពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនលេខាធិការនៃ គ.អ.ទ.ស.
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់លេខាធិការនៃ គ.អ.ទ.ស.។

**ប្រការ១៩._**

ផ្នែកសហប្រតិបត្តិការ និងផ្សព្វផ្សាយ មានតួនាទី និងភារកិច្ច ដូចតទៅ÷

- រៀបចំគម្រោងសហប្រតិបត្តិការជាមួយអង្គការ សមាគមជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ
- សម្របសម្រួល និងធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ជាតិ អន្តរជាតិ និងប្រទេសសមាជិកអាស៊ានលើរាល់សកម្មភាពដែលទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- តាមដាន និងវាយតម្លៃលើរាល់សកម្មភាព ដែលមានចែងក្នុងកំណត់ហេតុ អនុស្សរណៈនៃការយោគយល់គ្នា ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ជូនថ្នាក់ដឹកនាំពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- សម្របសម្រួល សហការ ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីគៀងគររកជំនួយ
- ជំរុញការចូលរួមពីសាធារណជន និងគ្រប់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- បង្កើត គ្រប់គ្រង រចនា និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ គ.អ.ទ.ស.
- ពិនិត្យ រៀបចំ និងចងក្រងគ្រប់ឯកសារផ្សព្វផ្សាយអំពីទេសចរណ៍សៀមរាប-អង្គរ
- ផ្សព្វផ្សាយព័ត៌មាន សំដៅបម្រើឱ្យការងារគ្រប់គ្រង និងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនលេខាធិការនៃ គ.អ.ទ.ស.
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់លេខាធិការនៃ គ.អ.ទ.ស.។

**ប្រការ២០._**

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចតទៅ÷

- ទទួលខុសត្រូវលើសេវាកម្មរដ្ឋបាលទូទៅ និងសម្របសម្រួលការងាររដ្ឋបាល ជូនគ្រប់អង្គភាពនៅក្រោមឱវាទលេខាធិការដ្ឋាននៃ គ.អ.ទ.ស.
- ទទួលខុសត្រូវលើការងារគ្រប់គ្រង ចាត់ចែង និងចរាចរឯកសាររដ្ឋបាលរបស់ គ.អ.ទ.ស.
- ធានាប្រសិទ្ធភាព សុវត្ថិភាព និងគ្រប់គ្រងការងាររដ្ឋបាល
- ទទួលបន្ទុករៀបចំសន្និបាត កិច្ចប្រជុំ សិក្ខាសាលា និងពិធីការនានា ព្រមទាំងធ្វើរបាយការណ៍ ឬកំណត់ហេតុ
